ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមីនា ឆ្នាំ២០២២

នៅក្នុងខែមីនា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន១លើក។

**ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ**

-បានទទួលសារតាំងពីឯកឧត្តម Buakeo PHUMVONGSAY ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងពិនិត្យ និងព្យាបាលព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខជាមួយក្រុមគ្រួសារសពអគ្គមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **លឹម ឈុន** ត្រូវជាឪពុកបង្កើត ឧកញ៉ា **អ៊ឹង ប៊ុនហ៊ាវ** នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមបុណ្យសពលោកជំទាវ **ច័ន្ទ ផល្លី** ជាភរិយារបស់ឯកឧត្តម



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

នាយឧត្តមសេនីយ៍ **ឈិន ច័ន្ទពណ៌** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ស្ថិតនៅភូមិ៨ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

-បានឧបត្ថម្ភថវិកាចំនួន១០,០០០ដុល្លារសហរដ្ឋអាមេរិក និង២០លានរៀលជូនកាកបាទក្រហមកម្ពុជា។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៨៨ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន៧៣ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៨៨ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៧២ច្បាប់

-ទទួលសំណើពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន១ច្បាប់

-បានចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២ច្បាប់ ផ្តល់យោបល់ចំនួន០៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ ភា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានបំពេញភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន១លើក។

**ក-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ នៅខណ្ឌព្រែកព្នៅ ខណ្ឌច្បារអំពៅ ខណ្ឌ៧មករា ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង ខណ្ឌឫស្សីកែវ ខណ្ឌចំការមន ខណ្ឌដង្កោ ខណ្ឌមានជ័យ ខណ្ឌកំបូល ខណ្ឌទួលគោក ខណ្ឌសែនសុខ និងខណ្ឌជ្រោយចង្វារ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់ ពិនិត្យណែនាំអំពីការផ្តល់សេវាសាធារណៈឱ្យបានល្អ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ។

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៣ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេង ឯន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញជាគណៈអធិបតីក្នុងពិធីសំណេះសំណាល និងសួរសុខទុក្ខជាមួយអាជ្ញាធរ ក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងខេត្តកណ្តាល សរុបចំនួន៩១៥នាក់។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមក្នុងពិធីបុណ្យពុទ្ធាភិសេក សាមញ្ញាភិសេក ឆ្លងព្រះចេតិយ និងអភិសេករូបបដិមា ឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធ លោកជំទាវ **អ៊ុច សំអាត** នៅខេត្តតាកែវ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត **ទី ថានី** អនុប្រធានទី១ អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលប្រជុំគណៈកម្មការទី៩ ព្រឹទ្ធសភា។

### ២.២ មុខងារតំណាង

-បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី២ ដើម្បីពិនិត្យឆ្លងផែនការចុះជួបក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំងភូមិភាគទី២ នៃខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ នៅសាលប្រជុំគណៈកម្មការទី៦ ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដើម្បីពិនិត្យ និងពិភាក្សាត្រៀមចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង នៅសាលប្រជុំគណៈកម្មការទី៨ ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៨ ដើម្បីពិនិត្យ និងពិភាក្សាត្រៀមចុះបេសកកម្មទៅតាមស្រុកនីមួយៗនាពេលខាងមុខ និងការងារផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិនិត្យពិភាក្សាលើការងារចុះបេសកកម្ម

របស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី២ ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមប្រជុំការងារតាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយមជ្ឈមណ្ឌលសភាអាស៊ី ស្តីពីការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "សិទ្ធិកាន់កាប់ដីធ្លី ការអនុវត្តច្បាប់ដីធ្លី និងកាលានុវត្តភាពនៃការអនុវត្តគោលនយោបាយសាធារណៈផ្នែកដីធ្លី ដើម្បីជាកត្តារួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងផលប្រយោជន៍របស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា" តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយប្រធានសមាគមមនុស្សចាស់ និងគណៈកម្មការកិច្ចការស្ត្រី និងកុមារ ដើម្បីស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារក្នុងខែកុម្ភៈ និងទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២២ ជាពិសេសខិតខំបង្កលក្ខណៈឱ្យមាតាបិតា និងអាណាព្យាបាលនាំកូនចៅ ដែលមានអាយុ២ឆ្នាំ ដល់៥ឆ្នាំ ទៅចាក់វ៉ាក់សាំងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅតាមគោលដៅដែលមន្ទីរសុខាភិបាលបានកំណត់ ស្ថិតនៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំឆ្លងរបាយការណ៍លទ្ធផលវគ្គបំប៉នពង្រឹងសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំ មន្ទីរ ខណ្ឌ សង្កាត់ នៃរាជធានីភ្នំពេញ និងកិច្ចប្រជុំសមាគមនារីរាជធានីភ្នំពេញ តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងមេភូមិ សរុបចំនួន៨៨នាក់ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធលើការងារមួយចំនួន ដូចជាការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តិ បញ្ហាប្រឈម តម្រូវការ និងសំណូមពរ ជុំវិញការអនុវត្តតួនាទី ភារកិច្ច របស់ខ្លួនដោយផ្តោតសំខាន់លើការងារផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព

-បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិជំណាក់កាលទី២ (២០២១-២០៣០) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមក្នុងសន្និបាតសមាគមមូលនិធិមនុស្សចាស់ ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

-បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសកែសម្រួល និងបំពេញបន្ថែមសមាសភាពគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តពោធិ៍សាត់

-បានអញ្ជើញផ្តល់បទសម្ភាសន៍ដល់ស្ថានីយ៍ទូរទស្សន៍ និងវិទ្យុអប្សរា ដើម្បីផលិតវីដេអូឯកសារស្តីពី " ទិវាអន្តរជាតិនារី ៨មីនា " នៅសាលប្រជុំគណៈកម្មការទី៨ ព្រឹទ្ធសភា

-បានអញ្ជើញផ្តល់បទសម្ភាសន៍ដល់អង្គការខាណា (KHANA) ក្នុងកម្មវិធីជជែកពិភាក្សាតុមូលសម្រាប់ចាក់ផ្សាយនៅលើកញ្ចក់ទូរទស្សន៍ ស្តីពី " កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្រោយការរាតត្បាត នៃជំងឺកូវីដ-១៩ ដើម្បីឆ្ពោះទៅសម្រេចបានគោលដៅនៃកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ ស្តីពីជំងឺរបេងឆ្នាំ២០២៣" នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមស្តាប់បទបង្ហាញនៃការស្រាវជ្រាវរបស់អង្គការLANSESA និង PIC/PCAsia តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញទទួលអំណោយ Computer ចំនួន២០គ្រឿង និងប្រដាប់វិនិច្ឆ័យរកមេរោគសត្វ ដែលជាអំណោយរបស់ Mr Boonsarng Prasitphol ក្នុងតម្លៃប្រមាណជា ១០០,០០០ដុល្លារ សម្រាប់យកមកបង្រៀននិស្សិតបំពេញចំណេះវិជ្ជាលើវិស័យកសិកម្ម និងឧស្សាហកម្ម

-បានអញ្ជើញចូលរួមក្នុងពិធីទទួលគ្រឿងឥស្សរិយយស(Insignes de Chevalier des Palmes accadémiques ) របស់កញ្ញា **គង់ សុមនី** ដែលត្រូវបានបំពាក់ដោយ

ឯកឧត្តម **Jacques Pellet** ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជា នៅនិវេសនដ្ឋាន នៃស្ថានទូតបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-បានទទួលពាក្យបណ្តឹងចំនួន៣ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៦ករណី កំពុងពិនិត្យសិក្សាចំនួន៦ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន៣ករណី

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន៨៥លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនៃការផ្តល់សេវាសាធារណៈ និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការសុខាភិបាល ស្តីពីវិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ចំនួន១៤៤លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តរតនគិរី ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។

## ២.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជាទៅចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤(IPU-144) និងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅនូហ្សាឌូ កោះបាលី សាធារណរដ្ឋឥណ្ឌូនេស៊ី

-លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ បានអនុញ្ញាតឱ្យប្រតិភូក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិផារ៉ាហ្គន PARAGON International School ដឹកនាំដោយលោក **Damir Musaev** នាយកប្រតិបត្តិនៃកម្មវិធីសាលាចូលជួប

សម្តែងការគួរសម និងជូនពរក្នុងឱកាសទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៥ ព្រឹទ្ធសភា

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ បានអញ្ជើញទទួលជួបជាមួយលោក Victor Come ជនជាតិអ៊ុយក្រែន មកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីបច្ចេកទេសដាំផ្កាចិញ្ចឹមឃ្មុំ នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ និងក្រុមអ្នកវិនិយោគទុនមកពីប្រទេសជប៉ុនចំនួន២រូប ដែលចង់បោះទុនវិនិយោគសាងសង់ភូមិឋានបែបបូរាណជប៉ុននៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេស-ចរណ៍ ម៉ុង ឫទ្ធីសែនជ័យ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

ជ.ប្រធានស្តីទីព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត ទេព ងន

<u>ចម្លងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ